ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

គោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត

Guideline on Flood Resilient Measurement For Water Supply

រៀបចំដោយ ៖ នាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង នៃអគ្គនាយកដ្ឋានទឹកស្អាត
ឧបត្ថម្ភ និងសហការចូលរួមដោយ ៖ អង្គការ UNICEF និង សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ០៩៩ MISTI / ២០២២

ប្រកាស
ស្តីពី
ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១.-

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់ សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដើម្បីចូលរួមបង្ការទប់ទល់ និងដោះស្រាយបន្ទាន់នូវហានិភ័យនានាដែលបង្កឡើងដោយគ្រោះទឹកជំនន់ និងធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

ប្រការ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតទាំងអស់ដែលស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេស ការផ្តល់សេវា

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ក្នុងពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smeminet@gmail.com

ផ្គត់ផ្គង់ទឹកស្អាតដែលមានទីតាំងផលិត និងចែកចាយទឹកស្អាត ស្ថិតក្នុងតំបន់ងាយទទួលរងនូវផលប៉ះពាល់ពីគ្រោះទឹកជំនន់។

ប្រការ៣.-

គោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់ គឺជាវិធានការចាំបាច់នានាសម្រាប់យកទៅអនុវត្តនៅមុនពេលមានគ្រោះទឹកជំនន់, ក្នុងកំឡុងពេលមានគ្រោះទឹកជំនន់ និងក្រោយពេលគ្រោះទឹកជំនន់ ដោយអនុវត្តចាប់ពីប្រភពទឹក ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹក និងបណ្តាញទឹកស្អាត រួមទាំងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធ។

ប្រការ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥.-

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៤ កើត ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០២២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត
- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

អារម្ភកថា

«ទឹក» គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យ និងការរស់នៅរបស់មនុស្សជាតិ។ ដោយមូលហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជាតែងតែផ្តល់អាទិភាពក្នុងការអភិវឌ្ឍវិស័យ «ទឹក» ក្នុងចំណោមវិស័យអាទិភាពទាំង ៤ គឺមនុស្ស ផ្លូវ ភ្លើង និងទឹក។ ទន្ទឹមនឹងនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្គត់ផ្គង់ទឹកស្អាតបានកំណត់ថា «*ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង ទីប្រជុំជនឱ្យបាន៩០% នៅឆ្នាំ២០២៣ និង ១០០% ត្រឹមឆ្នាំ២០២៥ សម្រាប់បម្រើតម្រូវការចាំបាច់របស់ប្រជាជន ក៏ដូចជាសម្រាប់ផលិតកម្ម និងសេវាកម្មនានា តាមរយៈការអភិវឌ្ឍពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ដោយឈរលើលក្ខខណ្ឌបួនយ៉ាងគឺ* ***ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ***»។

ដោយសារកត្តាធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ ជារឿយៗកម្ពុជាបានជួបប្រទះនូវគ្រោះទឹកជំនន់ ដែលធ្វើឱ្យមានការជន់លិច និងប៉ះពាល់ដល់គុណភាពប្រភពទឹក ព្រមទាំងដំណើរការធ្វើប្រព្រឹត្តិកម្ម និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត។ ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយខាងលើ ការធានាបាននូវនិរន្តរភាពសេវាផ្គត់ផ្គង់ទឹកស្អាត និងការកាត់បន្ថយហានិភ័យក្នុងពេលមានគ្រោះទឹកជំនន់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដាក់ឱ្យអនុវត្តនូវ **«គោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត»** ក្នុងបំណងចូលរួមបង្ការទប់ទល់ និងដោះស្រាយបន្ទាន់នូវហានិភ័យនានាដែលបង្កឡើងដោយគ្រោះទឹកជំនន់ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។ **គោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត** គឺបានដាក់ចេញវិធានការនានាសម្រាប់យកទៅអនុវត្តនៅមុនពេលមានគ្រោះទឹកជំនន់, ក្នុងកំឡុងពេលមានគ្រោះទឹកជំនន់ និងក្រោយពេលគ្រោះទឹកជំនន់ ដោយអនុវត្តចាប់ពីប្រភពទឹក ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹក និងបណ្តាញទឹកស្អាត ដោយក្នុងនោះក៏បានបង្ហាញពីការចូលរួមសហការរបស់អាជ្ញាធរមូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធ នៅតាមដំណាក់កាលនីមួយៗ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គោលការណ៍ណែនាំដ៏មានសារៈប្រយោជន៍នេះ នឹងត្រូវបានផ្សព្វផ្សាយ និងប្រើប្រាស់យ៉ាងទូលំទូលាយ ដោយមានការចូលរួមសហការយ៉ាងពេញលេញពីគ្រប់ភាគីពាក់ព័ន្ធ ទាំងផ្នែករដ្ឋ និងឯកជន ក្នុងបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដែលអាចកើតមានឡើងដោយគ្រោះទឹកជំនន់ សម្រាប់ជាឧត្តមប្រយោជន៍រួមរបស់ប្រជាជនកម្ពុជាទាំងមូល។

ជាចុងក្រោយ ក្នុងនាមក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងាររបស់អង្គការ UNICEF, សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការចូលរួមរៀបចំឯកសារគោលការណ៍ណែនាំនេះឡើង។ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះមន្ត្រីជំនាញ,

ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទឹកស្អាត និងថ្នាក់ដឹកនាំទទួលបន្ទុកទាំងអស់នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលបានខិតខំរៀបចំឯកសារ **គោលការណ៍ណែនាំស្តីពីវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត** ដ៏មានសារៈសំខាន់នេះ។

ថ្ងៃ ច្រហែ ឯកស័ក ខែភាទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០២២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

មាតិកា

ទំព័រ

១. សេចក្តីផ្តើម ១
២. គោលបំណង ១
៣. វិសាលភាព ២
៤. ការទទួលខុសត្រូវ ២
៥. វិធានការ ៣
៥.១. មុនពេលមានគ្រោះទឹកជំនន់ ៣
៥.១.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ ៣
៥.១.២. ត្រៀមការពារអាគារប្រព្រឹត្តិកម្មសម្អាតទឹក ៤
៥.១.៣. ត្រៀមការពារអាងស្តុកទឹកស្អាត ៤
៥.១.៤. ត្រៀមការចែកចាយទឹកស្អាត ៤
៥.១.៥. កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ៤
៥.២. អំឡុងពេលមានគ្រោះទឹកជំនន់ ៥
៥.២.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ ៥
៥.២.២. អាគារប្រព្រឹត្តិកម្មសម្អាតទឹក ៥
៥.២.៣. អាងស្តុកទឹកស្អាត ៦
៥.២.៤. ការចែកចាយទឹកស្អាត ៦
៥.២.៥. កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ៦
៥.៣. ក្រោយពេលមានគ្រោះទឹកជំនន់ ៧
៥.៣.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ ៧
៥.៣.២. អាគារប្រព្រឹត្តិកម្មសម្អាតទឹក ៧
៥.៣.៣. អាងស្តុកទឹកស្អាត ៧
៥.៣.៤. បណ្តាញទឹកស្អាត ៨
៦. ការធ្វើផែនការកែលម្អ ៨
៧. និយមន័យ ៨

១. សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាចម្បងមួយដែលប្រទេសជាច្រើននៅលើពិភពលោកបាននិងកំពុងតែមានការព្រួយបារម្ភ។ កម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ និងត្រូវបានទទួលស្គាល់ជាប្រទេសរងគ្រោះខ្លាំងជាងគេមួយនៅក្នុងតំបន់ ពីការប្រែប្រួលអាកាសធាតុ [1] ដោយសារសមត្ថភាពក្នុងការបន្សាំនៅមានកម្រិត ហើយហេដ្ឋារចនាសម្ព័ន្ធនៅមានភាពអន់ថយ ជាពិសេសនៅទីជនបទ [2] ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM)បានប៉ាន់ប្រមាណថា ទឹកជំនន់ក្នុងឆ្នាំ២០១៣ បានធ្វើឱ្យមានការខាតបង់ទៅលើវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងលំនៅដ្ឋានប្រជាពលរដ្ឋ ក្នុងទឹកប្រាក់ច្រើនជាង៣៥៥ លានដុល្លារ។[1] គណៈកម្មាធិការដែលបានរាយការណ៍ថា ទឹកជំនន់នេះបានប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៣៧៧ ៣៥៤គ្រួសារ (ប្រមាណ ១.៨លាននាក់) ក្នុងខេត្តចំនួន២០។ ទឹកជំនន់បានសម្លាប់មនុស្សអស់ចំនួន១៦៨នាក់ ដែលក្នុងនោះភាគច្រើនជាកុមារ ហើយសេវាសាធារណៈដូចជា វិស័យអប់រំ និងវិស័យសុខាភិបាល មិនអាចដំណើរការទៅបានដូចប្រក្រតីនោះទេ។[3] ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ទឹកស្អាត និងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងប្រព័ន្ធចែកចាយអគ្គីសនី(ទៅកាន់កន្លែងដែលអាចទៅដល់) ត្រូវបានខូចខាត ឬរងការបំផ្លិចបំផ្លាញ ដែលនេះជាទម្ងន់បន្ថែមលើផលប៉ះពាល់រយៈពេលវែង។

២. គោលបំណង

គោលការណ៍ណែនាំនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយបង្ការទប់ទល់ និងដោះស្រាយជាបន្ទាន់ទៅនឹងហានិភ័យគ្រោះទឹកជំនន់ ដើម្បីធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

គោលការណែនេះ មានគោលដៅដូចតទៅ៖

- ចាត់វិធានការត្រៀមបង្ការ និងកាត់បន្ថយផលប៉ះពាល់មុនពេលមានគ្រោះទឹកជំនន់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យ តាមដាន និងចាត់វិធានការដោះស្រាយជាបន្ទាន់ក្នុងពេលមានគ្រោះទឹកជំនន់
- ត្រួតពិនិត្យ ធ្វើផែនការ និងស្តារឡើងវិញក្រោយពេលគ្រោះទឹកជំនន់។

[1] Arief A. Yusuf, Herminia A. Francisco. Mapping Analysis. *Climate Change Vulnerability Mapping for Southeast Asia*. EEPSEA: 2009. Accessed 5 May 2015. http://www.eepsea.org/pub/tr/12324196651Mapping_Report.pdf

[2] Nang, Phirun. Working paper. *Climate Change Adaptation and Livelihoods in Inclusive Growth: A Review of Climate Change Impacts and Adaptive Capacity in Cambodia*. CDRI: 2013. Accessed 4 May 2015. http://www.cdri.org.kh/webdata/download/wp/wp82e.pdf

៣. វិសាលភាព

គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេស ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានទីតាំងផលិត និងចែកចាយទឹកស្អាត ស្ថិតក្នុងតំបន់ងាយទទួលរងនូវផលប៉ះពាល់ពីគ្រោះទឹកជំនន់ ដូចជា ខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ពោធិ៍សាត់ និងរតនៈគិរី ដែលទទួលផលប៉ះពាល់ពីជំនន់ទឹកភ្លៀង និងខេត្តកំពង់ចាម ក្រចេះ ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង និងតាកែវ ដែលទទួលរងផលប៉ះពាល់ពីការជន់លេចនៃទឹកទន្លេសាប និងទន្លេមេគង្គ។

ផ្នែកសំខាន់ៗនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលត្រូវធ្វើការត្រួតពិនិត្យ និងចាត់វិធានការដោះស្រាយក្រោមវិសាលភាពនៃគោលការណ៍ណែនាំនេះ គឺ៖

១. ប្រភពទឹក និងស្ថានីយបូមទឹកឆៅ

២. រោងចក្រប្រព្រឹត្តិកម្មសម្អាតទឹក

៣. អាងស្តុកទឹកស្អាត និង

៤. បណ្តាញទឹកស្អាត និងការចែកចាយទឹកស្អាត។

៤. ការទទួលខុសត្រូវ

គ្រោះទឹកជំនន់តែងបង្កវផលវិបាកជាច្រើនដល់មនុស្សជាតិ។ ចំពោះប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតវិញ ទឹកជំនន់តែងបណ្តាលឱ្យ៖

- គុណភាពទឹកឆៅធ្លាក់ចុះ ធ្វើឱ្យពិបាកសម្អាត ឬ តម្រូវឱ្យចំណាយវត្ថុធាតុដើមច្រើន និងចំណាយច្រើនក្នុងការសម្អាត
- បាក់ច្រាំង និងប៉ះពាល់ដល់ស្ថានីយបូម ឬ បណ្តាញទឹកឆៅ
- ខូចខាត ឬ បាត់បង់ភាគខ្លះ ឬ ទាំងស្រុងនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- បង្អាក់ការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ខ្លះ ឬ ទាំងស្រុងតែម្តង។

ដោយហេតុដូចនេះ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះទឹកជំនន់ដល់ការផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករចាំបាច់ត្រូវកំណត់បញ្ហាប្រឈម និងរៀបចំផែនការសកម្មភាពមួយជាក់លាក់ ដោយរួមបញ្ចូលទាំងផែនការថវិកាសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។ ទន្ទឹមនឹងនេះ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតត្រូវស្នើសុំកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ក្នុងការចូលរួមថែរក្សាអនាម័យ និងជៀសវាងការបំផ្លាញប្រព័ន្ធចែកចាយទឹកស្អាត ដើម្បីជាប្រយោជន៍សម្រាប់ទាំងអស់គ្នា។

៥. វិធានការ

៥.១. មុនពេលមានគ្រោះទឹកជំនន់

វិធានការត្រៀមបង្ការ និងកាត់បន្ថយផលប៉ះពាល់ ត្រូវធ្វើឡើងមុនពេលមានគ្រោះទឹកជំនន់ គឺដើមរដូវវស្សា ក្នុងអំឡុងខែមេសានិងឧសភា។ វិធានការចាំបាច់ដែលត្រូវអនុវត្តមុនពេលទឹកជំនន់ មានដូចខាងក្រោម៖

៥.១.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ

- តាមដានព័ត៌មានឧតុនិយមពីរបបទឹកភ្លៀងនិងបញ្ហាគ្រោះទឹកជំនន់ ដែលអាចនឹងប៉ះពាល់ដល់តំបន់សេវាកម្មរបស់ខ្លួន តាមរយៈ
    - បទពិសោធន៍ទឹកជំនន់ក្នុងឆ្នាំកន្លងទៅ
    - វិទ្យុ និង ទូរទស្សន៍
    - Facebook របស់ក្រសួងធនធានទឹកនិងឧតុនិយម
    - Facebook របស់មន្ទីធនធានទឹកនិងឧតុនិយមក្នុងខេត្តរបស់ខ្លួន
    - បណ្តាញសារព័ត៌មានសង្គមផ្សេងៗ។
- តាមដាននិងកត់ត្រាបម្រែបម្រួលកម្ពស់ប្រភពទឹក ដោយប្រើឧបករណ៍ក្រិតកម្ពស់ ដើម្បីប៉ាន់ស្មានទុកជាមុននូវផលប៉ះពាល់នានាដែលអាចកើតមានឡើងចំពោះស្ថានីយបូមទឹកឆៅ និងគុណភាពទឹកឆៅ
- ត្រួតពិនិត្យ និងមានវិធានការការពារសកម្មភាពបំពុលនានាជុំវិញប្រភពទឹក ដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកឆៅ ព្រមទាំងរាយការណ៍ និងស្នើសុំអន្តរាគមន៍ពីស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ក្នុងករណីចាំបាច់
- ក្នុងករណីប្រភពទឹក ជាទឹកនឹង (ស្រះ បឹង ទំនប់ ។ល។) ត្រូវលើកទំនប់ព័ទ្ធជុំវិញប្រភពទឹក និង/ឬ ធ្វើប្រព័ន្ធបិទបើកទឹក ដើម្បីការពារប្រភពទឹកតាមជាក់ស្តែង
- ក្នុងករណីប្រភពទឹក ជាទឹកក្រោមដី (អណ្តូង ឬ ទឹកប្រភពហូរចេញពីក្រោមដី) ត្រូវការពារការហូរចូលទឹកពីក្រៅ (តាមស្ថានភាពជាក់ស្តែង) ដើម្បីការពារគុណភាពទឹក
- ក្នុងករណីប្រភពទឹក ជាទឹកលើដី (ស្ទឹង ព្រែក អូរ ប្រឡាយ ទន្លេ ។ល។) ត្រូវធ្វើប្រពន្ធ័ការពារស្ថានីយបូមទឹកឆៅទប់ទល់នឹងការជន់លិច ឬ លើកកល់ម៉ូទ័របូមទឹកឆៅឱ្យខ្ពស់ផុតពីជំនន់ ក្នុងករណីស្ថានីយបូមលើគោក និងពង្រឹងការការពារកុំឱ្យរសាត់ ឬ ក្រឡាប់ករណីស្ថានីយបណ្តែត
- ត្រួតពិនិត្យប្រព័ន្ធចរន្តអគ្គិសនី ដើម្បីការពារការលិចលង់ និងធានានូវសុវត្ថិភាពបូម

- បង្កើនការតាមដាន និងត្រួតពិនិត្យការប្រែប្រួលគុណភាពប្រភពទឹកដូចជា សីតុណ្ហភាព ប៉េហាស ភាពល្អក់ និងភាពរឹងរលាយសរុប សម្រាប់ជាមូលដ្ឋានក្នុងការធ្វើដ្យាតេស្តដើម្បីកំណត់ការប្រើប្រាស់សារធាតុគីមីឱ្យបានត្រឹមត្រូវ
- លើកស្លាកសញ្ញាសម្គាល់ទីតាំងស្ថានីយបូមទឹកឆៅ ជៀសវាងគ្រោះថ្នាក់ដោយប្រការផ្សេងៗ។

៥.១.២. ត្រៀមការពារអេឆក្រុប្រព្រឹត្តិកម្មសម្អាតទឹក

- ត្រួតពិនិត្យប្រព័ន្ធចរន្តអគ្គិសនី និងតំណខ្សែភ្លើងក្នុងទីតាំងស្ថានីយប្រព្រឹត្តិកម្ម ដើម្បីការពារហានិភ័យពេលទឹកជន់លិច។ ត្រៀមម៉ាស៊ីនភ្លើង និងប្រេងឥន្ធនៈ ដើម្បីបង្ការក្នុងពេលដាច់ចរន្តអគ្គិសនី។
- ត្រួតពិនិត្យឃ្លាំងស្តុកសារធាតុគីមីឱ្យមានបរិមាណគ្រប់គ្រាន់ ជានាការប្រើប្រាស់ក្នុងរយៈពេលបីខែយ៉ាងតិច និងជានាស្តុកជៀសវាងការជន់លិចដែលបណ្តាលឱ្យខូចខាត
- ថែទាំ ឬ ជួសជុលប្រព័ន្ធបញ្ចូលសារធាតុគីមី ដើម្បីជានាប្រសិទ្ធភាពនៃការសម្អាតទឹក រួមទាំងប្រព័ន្ធបញ្ចូលក្លរដំបូង (Pre-Chlorine) (ករណីប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតទឹកមានការបញ្ចូលក្លរដំបូង)
- ត្រៀមបាវខ្សាច់ សម្រាប់លើកជាទំនប់ការពារស្ថានីយ ក្នុងករណីចាំបាច់។

៥.១.៣. ត្រៀមការពារអេឆស្តុកទឹកស្អាត

- ពិនិត្យអាងស្តុកទឹកស្អាតនិងការពារកុំឱ្យទឹកជំនន់ហូរចូលទៅក្នុងអាងស្តុក (ត្រៀមបាវខ្សាច់សម្រាប់លើកជាទំនប់ការពារ)
- ត្រួតពិនិត្យ និងថែទាំ ឬ ជួសជុលប្រព័ន្ធបញ្ចូលក្លរចុងក្រោយ (Post-Chlorine) ឱ្យជានាដំណើរការជាប្រក្រតី។

៥.១.៤. ត្រៀមការចែកចាយទឹកស្អាត

- ត្រួតពិនិត្យនិងការពារការជន់លិចទីតាំងស្ថានីយបូមរុញចែកចាយទឹកស្អាត រួមទាំងប្រព័ន្ធអគ្គិសនី និងម៉ាស៊ីនភ្លើង
- ត្រៀមបាវខ្សាច់ សម្រាប់លើកជាទំនប់ការពារស្ថានីយបូម ក្នុងករណីចាំបាច់
- ត្រៀមសម្ភារនិងឧបករណ៍សម្រាប់ជួសជុលនិងផ្លាស់ប្តូរ នាឡិកាទឹក វ៉ាន ក៏ដូចជាទុយោទឹកដែលអាចលេចធ្លាយដាយថាហេតុ។

៥.១.៥. កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន

- សហការជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការអប់រំនិងផ្សព្វផ្សាយដល់អតិថិជន ឱ្យត្រៀមរៀបចំប្រព័ន្ធទឹកក្នុងបរិវេណលំនៅដ្ឋាន និងស្តុកទឹកសម្រាប់ប្រើប្រាស់ប្រកបដោយសុវត្ថិភាព និង

អនាម័យ ព្រមទាំងឱ្យយល់ដឹងពីបញ្ហាគ្រោះទឹកជំនន់ដែលអាចប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាតជាយថាហេតុ

- ករណីចាំបាច់ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងការកំណត់ទីទួលសុវត្ថិភាព ដើម្បីត្រៀមផ្គត់ផ្គង់ទឹកស្អាតជាលក្ខណៈបណ្តោះអាសន្ន។

៥.២. អំឡុងពេលមានគ្រោះទឹកជំនន់

ការត្រួតពិនិត្យ តាមដាន និងការចាត់វិធានការដោះស្រាយត្រូវធ្វើជាបន្ទាន់ បន្ទាប់ពីទទួលបានព័ត៌មានស្តីពីគ្រោះជំនន់នៅក្នុងតំបន់របស់ខ្លួន។ គ្រោះទឹកជំនន់ភាគច្រើនតែងកើតឡើងក្នុងពេលដែលរបបទឹកភ្លៀងឡើងខ្ពស់។ វិធានការចាំបាច់ដែលត្រូវអនុវត្តក្នុងអំឡុងពេលមានគ្រោះទឹកជំនន់នេះ មានដូចខាងក្រោម៖

៥.២.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ

- ចាត់បុគ្គលិកប្រចាំការរាល់ថ្ងៃនៅស្ថានីយបូមទឹកនៅ(២៤ម៉ោង/ថ្ងៃ) ដើម្បីត្រួតពិនិត្យ និងតាមដានស្ថានភាពទឹកជំនន់ និងចាត់វិធានការតាមការចាំបាច់
- ត្រួតពិនិត្យ និងតាមដានបង្ការនូវការបាក់ទំនប់ព័ទ្ធជុំវិញប្រភពទឹក និង/ឬ ប្រព័ន្ធបិទបើកទឹក (ករណីប្រភពទឹកនឹង) ឬ ការហូរចូលទឹកពីក្រៅ (ករណីទឹកអណ្តូង)
- បង្កើនការត្រួតពិនិត្យ បង្ការការឆ្លងចរន្តអគ្គិសនី
- ត្រួតពិនិត្យស្លាកសញ្ញាសម្គាល់ទីតាំងប្រភពទឹក ជៀសវាងគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស និងសត្វ
- បង្កើនការត្រួតពិនិត្យ ថែទាំ និងជួសជុលប្រព័ន្ធបូមទឹក ជៀសវាងការកកស្ទះ
- បង្កើនការតាមដាន និងត្រួតពិនិត្យការប្រែប្រួលគុណភាពប្រភពទឹកដូចជា សីតុណ្ហភាព ប៉ែហាស ភាពល្អក់ និងភាពរឹងរលាយសរុប សម្រាប់ជាមូលដ្ឋានក្នុងការធ្វើដ្យាតេស្តដើម្បីកំណត់ការប្រើប្រាស់សារធាតុគីមីឱ្យបានត្រឹមត្រូវ។

៥.២.២. រោងចក្រប្រព្រឹត្តិកម្មសម្អាតទឹក

- ធានាការស្តុកសារធាតុគីមីប្រកបដោយសុវត្ថិភាព
- បង្កើនការត្រួតពិនិត្យប្រព័ន្ធអគ្គិសនី ក្នុងករណីទឹកលេចរោងចក្រប្រព្រឹត្តិកម្មសម្អាតទឹក
- បង្កើនការថែទាំ ឬ ជួសជុលប្រព័ន្ធបញ្ចូលសារធាតុគីមី (សាច់ជូរ ឬ PAC, កំបោរ) និងក្លរដំបូង (Pre-chlorine)
- ការពារ និងអនាម័យលើអាងប្រព្រឹត្តិកម្មសម្អាតទឹក
- បង្កើនការលាងអាងប្រព្រឹត្តិកម្មសម្អាតទឹក
- បង្កើនការត្រួតពិនិត្យការលេចជ្រាបទឹកតាមរ៉ាន និងការបាក់បែកទុយោទឹកក្នុងស្ថានីយ

- ត្រួតពិនិត្យការធ្វើប្រព្រឹត្តិកម្មសម្អាតទឹក ចាប់ពីអាងលាយសារធាតុគីមីរហូតដល់អាងច្រោះខ្សាច់ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការប្រើប្រាស់សារធាតុគីមី
- ត្រួតពិនិត្យស្ថានភាពដីជុំវិញអាងប្រព្រឹត្តិកម្ម និងចាត់វិធានការជាបន្ទាន់ដើម្បីជៀសវាងការហូរច្រោះដី។

៥.២.៣. អាងស្តុកទឹកស្អាត

- បង្កើនការត្រួតពិនិត្យ និងបង្ការការលេចជ្រាប ឬហូរទឹកមិនស្អាតចូលអាងស្តុកទឹកស្អាត
- ពិនិត្យប្រព័ន្ធបញ្ចូលក្លរចុងក្រោយ (Post-Chlorine) ឱ្យធានានូវដំណើរការជាប្រក្រតី
- ត្រួតពិនិត្យស្ថានភាពដីជុំវិញអាងស្តុកទឹកស្អាត និងចាត់វិធានការជាបន្ទាន់ដើម្បីជៀសវាងការហូរច្រោះដី។

៥.២.៤. ការចែកចាយទឹកស្អាត

- ធានាសម្ភារ និងតំណតភ្ជាប់ក្នុងករណីទឹករលេចធ្លាយ
- បង្កើនការយកចិត្តទុកដាក់កត់ត្រាបរិមាណទឹកចែកចាយ
- តាមដានបណ្តាញចែកចាយទឹកស្អាតតាមតំបន់នីមួយៗជាប្រចាំ និងជួសជុលជាបន្ទាន់ករណីរកឃើញមានការរលេចធ្លាយ
- ត្រូវត្រួតពិនិត្យសម្ពាធនៅទីតាំងស្ថានីយប្រព្រឹត្តិកម្ម និងចុងបណ្តាញជាប្រចាំ ដើម្បីមានវិធានការសមស្រប
- ត្រៀមកន្លែងផ្តល់ទឹកស្អាតជូនប្រជាជននៅទីតាំងស្ថានីយ។

៥.២.៥. កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន

- សហការជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការអប់រំនិងផ្សព្វផ្សាយដល់អតិថិជន ឱ្យស្តុកទឹកសម្រាប់ប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងអនាម័យ (ឧទាហរណ៍៖ ពងទឹកត្រូវមានគំរបឱ្យបានត្រឹមត្រូវ និងមិនត្រូវលេចឡើយ) ព្រមទាំងឱ្យយល់ដឹងពីបញ្ហាគ្រោះទឹកជំនន់ដែលអាចប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាតជាយថាហេតុ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងការផ្គត់ផ្គង់ទឹកស្អាតជាលក្ខណៈបណ្តោះអាសន្ន ដល់ទីទួលសុវត្ថិភាព
- ក្នុងករណីប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវសុំកិច្ចសហការនិងការគាំទ្រពីអាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តការផ្គត់ផ្គង់ទឹកស្អាត ឱ្យអស់លទ្ធភាព
- ក្នុងករណីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមិនអាចបន្តដំណើរការតទៅទៀតបាន ត្រូវរាយការណ៍ជូននិងស្នើសុំការអនុញ្ញាតពីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងខេត្ត

របស់ខ្លួន ហើយសហការជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការជូនដំណឹងដល់អតិថិជន ពីការផ្អាកការផ្គត់ផ្គង់ទឹកស្អាត

- ណែនាំឱ្យអតិថិជនត្រួតពិនិត្យបណ្តាញ និងនាឡិកាទឹកក្នុងបរិវេណលំនៅដ្ឋាននីមួយៗ ជៀសវាងការលេចធ្លាយ។

៥.៣. ក្រោយពេលមានគ្រោះទឹកជំនន់

ការងារត្រួតពិនិត្យ ការធ្វើផែនការ និងការស្តារឡើងវិញនូវផលប៉ះពាល់ទាំងឡាយដោយសារគ្រោះទឹកជំនន់ ត្រូវធ្វើឡើងនៅក្រោយពេលគ្រោះទឹកជំនន់ ដោយត្រូវបែងចែកជាការងារបន្ទាន់ត្រូវអនុវត្តភ្លាមៗ និងការងារមិនបន្ទាន់ ដែលជាទូទៅត្រូវអនុវត្តនៅដើមរដូវប្រាំង។

វិធានការចាំបាច់ដែលត្រូវអនុវត្តក្រោយពេលគ្រោះទឹកជំនន់ មានដូចខាងក្រោម៖

៥.៣.១. ប្រភពទឹក និងស្ថានីយបូមទឹកនៅ

- ពិនិត្យ និងជួសជុលទំនប់ទឹកជាបន្ទាន់ (ដោយសហការជាមួយស្ថាប័ន/អាជ្ញាធរពាក់ព័ន្ធករណីទំនប់ទឹកក្រោមការគ្រប់គ្រងរបស់ស្ថាប័ន/អាជ្ញាធរ) ដើម្បីរក្សាទឹកទុកសម្រាប់ប្រើប្រាស់
- បង្កើនការតាមដាន និងត្រួតពិនិត្យការប្រែប្រួលគុណភាពប្រភពទឹកដូចជា សីតុណ្ហភាព ប៉ែហាស ភាពល្អក់ និងភាពរឹងរលាយសរុប សម្រាប់ជាមូលដ្ឋានក្នុងការធ្វើដ្យាតេស្តដើម្បីកំណត់ការប្រើប្រាស់សារធាតុគីមីឱ្យបានត្រឹមត្រូវ
- ស្វែងរកអ្នកជំនាញ ដើម្បីប្រឹក្សាយោបល់រកដំណោះស្រាយ និងធ្វើផែនការកែលម្អ កាត់បន្ថយផលប៉ះពាល់នៅពេលក្រោយ
- ស្វែងរកការគាំទ្រពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ឬ ប្រភពហិរញ្ញប្បទាននានា ដើម្បីអភិវឌ្ឍ និងការពារប្រភពទឹក។

៥.៣.២. អេតចក្រប្រព្រឹត្តិកម្មសម្អាតទឹក

- ថែទាំ ឬ ជួសជុលប្រព័ន្ធបញ្ចូលសារធាតុគីមី និងក្លរដំបូង (Pre-chlorine)
- កែលម្អ ឬ ជួសជុលការលេចជ្រាប និងសម្ភារដែលខូចដោយសារលេចទឹក
- លាងសម្អាតអាងប្រព្រឹត្តិកម្មជាប្រចាំ និងទៀងទាត់តាមលក្ខណៈបច្ចេកទេស។

៥.៣.៣. អេតស្តុកទឹកស្អាត

- ពិនិត្យ ថែទាំ និងជួសជុលអាងស្តុកទឹកស្អាតជៀសវាងមានការលេចជ្រាប
- លាងសម្អាតអាងស្តុកទឹកទាំងមូល ក្នុងករណីអាងស្តុកនោះបានលិចក្នុងអំឡុងពេលទឹកជំនន់
- ពិនិត្យ ថែទាំ និងជួសជុលប្រព័ន្ធបញ្ចូលក្លរចុងក្រោយ (Post-Chlorine)

- ពង្រឹងការធ្វើតេស្តលើប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្តប្រចាំថ្ងៃ(ប៉េហាស ភាពល្អក់ ពណ៌ ភាពរឹង រលាយសរុប និងក្លរសំណល់) ជានាឆ្លើយតបទៅនឹងស្តង់ដារគុណភាពទឹកស្អាតថ្នាក់ជាតិ។

៥.៣.៤. បណ្តាញទឹកស្អាត

- ត្រួតពិនិត្យនាឡិកាទឹក (នាឡិកាមេ នាឡិកាតាមតំបន់ និងនាឡិកាតាមផ្ទះ) និងធ្វើការផ្លាស់ប្តូរក្នុងករណីរកឃើញមានការខូច ឬ គាំង
- ធ្វើការលាងបណ្តាញចែកចាយ តាមស្ថានភាពជាក់ស្តែង និង/ឬ ក្នុងករណីចាំបាច់
- ជួសជុលទុយោដែលលេចធ្លាយ ឬ ផ្លាស់ប្តូរទុយោតាមអាយុកាលនៃការប្រើប្រាស់ និង/ឬ គុណភាព។

៦. ការធ្វើផែនការកែលម្អ

ដើម្បីឱ្យប្រាកដថា ការកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតត្រូវបានអនុវត្តក្នុងគោលបំណងធានានូវនិរន្តភាពនៃការផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករទឹកស្អាតត្រូវរៀបចំផែនការកែលម្អ ដោយផ្អែកលើព័ត៌មាននៃផលប៉ះពាល់ខាងលើ។ ផែនការកែលម្អនេះ មានបញ្ជាក់ច្បាស់ពី៖

- បញ្ហាដែលជួបប្រទះ និងដំណោះស្រាយ
- អ្នកទទួលខុសត្រូវក្នុងការអនុវត្ត
- សកម្មភាពដែលត្រូវធ្វើ
- ពេលវេលាក្នុងការអនុវត្តសកម្មភាព
- លទ្ធផលរំពឹងទុក
- ថវិកាប៉ាន់ស្មាន និងប្រភពថវិកា។

៧. និយមន័យ

- **គ្រោះទឹកជំនន់** គឺជាបញ្ហាធម្មជាតិចម្បង ដែលបណ្តាលមកពីការកើនឡើងនៃបរិមាណទឹកជាគំហុក និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ និងប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ និងរុក្ខជាតិ
- **ការប្រែប្រួលអាកាសធាតុ** គឺជាដំណើរការប្រែប្រួលបន្តិចម្តងៗនៃអាកាសធាតុ ក្នុងរយៈពេលវែង ក្នុងនោះរួមមាន សីតុណ្ហភាព របបទឹកភ្លៀង របបខ្យល់ គម្របទឹកកកជាដើម។ ការប្រែប្រួលនេះកើតឡើងដោយសារកត្តាធម្មជាតិ និងសកម្មភាពរបស់មនុស្ស ឬជាការបកស្រាយយោងទៅតាមស្ថិតិស្តីអំពី លំនាំអាកាសធាតុដែលមានការប្រែប្រួលក្នុងរយៈពេលវែងមួយ
- **ភាពធន់/ភាពធន់ទ្រាំ** គឺជាសមត្ថភាពនៃប្រព័ន្ធសង្គម-អេកូឡូស៊ី ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍គ្រោះថ្នាក់ ឬការរំខានណាមួយ ដែលអាចឆ្លើយតបឬចាត់ចែងឡើងវិញតាមវិធីដែលអាចរក្សាបាននូវមុខងារសំខាន់ៗ អត្តសញ្ញាណ និងរចនាសម្ព័ន្ធ ហើយដែលអាចរក្សាបាននូវសមត្ថភាពបន្សាំ ការរៀនសូត្រ និងច្នៃប្រឌិត។